ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៨ លេខ ១ | ខែមិនា ២០១៤ | តម្លៃ ១.៥០០៛

# សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១៤៖ កម្ពុជាក្នុងប្រាំឆ្នាំទៅមុខ - កំណែទម្រង់ និង ភាពប្រកួតប្រជែងក្នុងតំបន់ក្រោយធ្វើសមាហរណកម្ម

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា លើកទី៨ ដែលជាកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal បានប្រារព្ធឡើងនៅថ្ងៃទី ២៧ កុម្ភៈ ២០១៤ នៅរាជធានីភ្នំពេញ។ ថ្នាក់ដឹកនាំមកពីខាង រដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ សហគមន៍ស្រាវជ្រាវ និង NGOs បានមកជួបជុំគ្នា ដើម្បីពិភាក្សាលើប្រធានបទ "កម្ពុជាក្នុងប្រាំឆ្នាំទៅមុខ - កំណែទម្រង់ និង ភាពប្រកួតប្រជែង នៅក្នុងតំបន់ក្រោយធ្វើសមាហរណកម្ម"។ នៅក្នុងសុន្ទរកថាគន្លឹះបើកសន្និសីទ សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសំដែងការសាទរ ចំពោះភាពជាដៃគូរយៈពេលវែងប្រកបដោយផ្លែផ្កា រវាង CDRI និង ANZ Royal និងបានគូសបញ្ជាក់ពីតួនាទីដ៏សំខាន់នៃសន្និសីទនេះក្នុងការផ្ដល់ព័ត៌មានដល់រដ្ឋាភិបាលអំពីវិស័យដែលត្រូវធ្វើសកម្មភាពខាងគោលនយោបាយ។ អត្ថបទនេះ គូសបញ្ជាក់ពីបញ្ហាខាងគោលនយោបាយសំខាន់ៗ ដែលអ្នកចូលរួមបានលើកឡើងក្នុងវគ្គនានានៃសន្និសីទ។




*ឯ.ឧ. បណ្ឌិត សុក ស៊ីផាន់ណា ប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថាន CDRI ថ្លែងសុន្ទរកថាស្វាគមន៍ក្នុងពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់នៃ សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។*

## សេចក្ដីផ្ដើម

របៀបវារៈសន្និសីទចក្ខុវិស័យឆ្នាំ២០១៤ បញ្ជាក់ពីការយកចិត្តទុកដាក់ជាថ្មីលើកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការធ្វើពិពិធកម្ម និងបង្កើនភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា ដើម្បីបង្ហាញនូវការពិតពីរគឺ ស្ថានភាពប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងពេលឆាប់ៗខាងមុខ និងការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ក្នុងឆ្នាំ២០១៥។

បន្ទាប់ពីសម្រេចបានកំណើន ផសស ខ្ពស់ក្នុងពីរទសវត្សរ៍កន្លងទៅនេះ កម្ពុជាមានសេដ្ឋកិច្ចកាន់តែស្មុគស្មាញ ហើយរំពឹងថានឹងឡើងឋានៈជា ប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងពេលឆាប់ៗខាងមុខ។ នៅពេលដែល ផសស ក្នុងមនុស្សម្នាក់កើនឡើង ប្រភពកំណើនថ្មីៗត្រូវតែបំប៉នពង្រឹងឡើង ហើយកត្តាស្នូលនៃកំណើនកន្លងមក ពោលគឺ ពលកម្មមានតម្លៃទាបនឹងត្រូវបាត់បង់។ ម្យ៉ាងទៀត ការចូលរួមក្នុង AEC នឹងធ្វើឲ្យប្រែប្រួលដល់ទំនាក់ទំនងរបស់កម្ពុជា ជាមួយប្រទេសដទៃទៀតក្នុងតំបន់ ដូច្នេះត្រូវមានកម្មវិធីកែតម្រូវរចនាសម្ព័ន្ធសេដ្ឋកិច្ច ដើម្បីអាចចាប់យកអត្ថប្រយោជន៍ពីកំណើនវិនិយោគ និងពាណិជ្ជកម្មក្នុងតំបន់។

អត្ថបទនេះ រៀបរៀងដោយ Benjamin C. R. Flower, គឹម សួ, រ័ត្ន វឌ្ឍនា និង ស៊ុំ ស្រីមុំ ជាអ្នកស្រាវជ្រាវ នៃវិទ្យាស្ថាន CDRI។ អត្ថបទនេះ ផ្អែកលើបទបង្ហាញនៅក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៤ និងអត្ថបទសង្ខេបចក្ខុវិស័យកម្ពុជា មានចុះនៅក្នុងគេហទំព័ររបស់វិទ្យាស្ថាន CDRI៖ www.cdri.org.kh។ សូមយោងឯកសារនេះថា៖ Flower, Benjamin C.R., with Kim Sour, Roth Vathana and Sum Sreymom (2014), *"Cambodia Outlook Conference 2014: The Next Five Years - Reform and Competiveness in an Integrated Region"*, Cambodia Development Review, 18(1):1-7។

## មាតិកា

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១៤៖ កម្ពុជាក្នុងប្រាំឆ្នាំទៅមុខ - កំណែទម្រង់ និងភាពប្រកួតប្រជែងក្នុងតំបន់ក្រោយធ្វើសមាហរណកម្ម .......... ១
ជម្រើសក្នុងការស្តុកទឹកសម្រាប់កសិកម្ម ដើម្បីសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា.......... ៨
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស .......... ១៤
— ស្ថានភាពក្នុងប្រទេស.......... ១៦
— សូចនាករ.......... ១៨
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI .......... ២៤

ការឈានឡើងក្នុងពេលខាងមុខនេះ មិនត្រឹមតែមានផលពាក់ព័ន្ធដល់គោលនយោបាយសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែក៏មានទិដ្ឋភាពសំខាន់ៗខាងគោលនយោបាយ និងសង្គមផងដែរ។ រដ្ឋាភិបាលបានទទួលស្គាល់ថា ឆ្លងតាមឧស្សាហូបនីយកម្ម នគរូបនីយកម្ម និង កំណើន ផសស ក្នុងមនុស្សម្នាក់នោះ កម្រិតជីវភាពដែលប្រជាជនចង់បាន និងក្ដីរំពឹងសង្ឃឹមទៅលើប្រព័ន្ធគោលនយោបាយ គឺកំពុងតែផ្លាស់ប្ដូរហើយ។ ការបំពេញបានទៅតាមបំណងប្រាថ្នានេះ សំខាន់ខ្លាំងណាស់សម្រាប់ជោគជ័យក្នុងដំណាក់កាលខាងមុខនៃកំណើន។ ដូច្នេះ របៀបវារៈនៃសន្និសីទចក្ខុវិស័យនេះ ក៏បានបញ្ជាក់ពីការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការដើរតាមគន្លងកំណែទម្រង់សេដ្ឋកិច្ចមួយ នៅក្នុងក្របខ័ណ្ឌដ៏ធំទូលាយនៃការអភិវឌ្ឍសម្រាប់គ្រប់គ្នា។

អត្ថបទនេះ បង្ហាញពីអាទិភាពគោលនយោបាយធំៗមួយចំនួនដែលមានលើកឡើងនៅក្នុងសន្និសីទ។ ផ្នែកទី១ រៀបរាប់ពីគោលដៅរបស់រដ្ឋាភិបាល ក្នុងការប្រែក្លាយកំណើនកម្រិតខ្ពស់ឲ្យទៅជាកំណើនសម្រាប់គ្រប់គ្នា ដោយគូសបញ្ជាក់ពីបញ្ហាបច្ចុប្បន្ននៃកម្មសិទ្ធិដីមានសុវត្ថិភាព។ ផ្នែកទី២ បង្ហាញពីការអភិវឌ្ឍធនធានមនុស្ស ថាជាវិស័យជាអាទិភាពមួយសម្រាប់ជំរុញពិពិធកម្ម និងបង្កើនភាពប្រកួតប្រជែង តាមការផ្ដល់លទ្ធភាពឲ្យប្រជាជនកម្ពុជា ចូលរួមចំណែកកាន់តែមានផលិតភាពខ្ពស់ឡើងនៅក្នុងសេដ្ឋកិច្ច។ ផ្នែកទី៣ គឺ ការពិនិត្យជារួមពីឧបសគ្គផ្សេងៗចំពោះអាជីវកម្ម ដោយផ្ដោតលើការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ហើយផ្នែកទី៤ ផ្ដោតលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅកម្ពុជា ដែលកំពុងបង្កឧបសគ្គដល់ការអភិវឌ្ឍសេដ្ឋកិច្ច។

## ការកសាងមូលដ្ឋានគ្រឹះ ដើម្បីកំណើនខ្លាំង និងសម្រាប់គ្រប់គ្នា

ដោយមានមូលដ្ឋានគ្រឹះជា កំណើន ផសស ខ្លាំងតាមអត្រាប្រចាំឆ្នាំជាមធ្យម ៧,៨% ពីឆ្នាំ១៩៩៤-២០១១ កម្ពុជាកំពុងឈានចូលក្នុងដំណាក់កាលបន្ទាប់នៃការរីកលូតលាស់ ដោយមានអត្រាកំណើន ៧,៦% សម្រាប់ឆ្នាំ២០១៣ និងអត្រាកំណើនប្រចាំឆ្នាំតាមការគន់គូរ ដល់ ៧% សម្រាប់ប្រាំឆ្នាំខាងមុខទៀត។ នៅឆ្នាំ២០១៣ ការនាំចេញសរុប កើន ១៦,២% ស្មើនឹង ៦,៩៩ ពាន់លានដុល្លារ ដែលជំរុញឡើងដោយការលូតលាស់ខ្លាំងក្នុងវិស័យស្នូលនានានៃសេដ្ឋកិច្ច។ ការនាំចេញសម្លៀកបំពាក់កើន ១៧,៣% ការនាំចេញស្បែកជើងកើន ២១,៣% ហើយវិស័យទេសចរណ៍កើន ១៧,៣%។ ការនាំចេញអង្ករកើន ៥៤% ដល់ ៣៧៩.០០០តោន ដែលបង្ហាញនូវនិន្នាការកំណើនខ្លាំងជាបន្តក្នុងផលិតកម្មស្រូវអង្ករចាប់តាំងពីឆ្នាំ២០០៩ មក (រូបភាព ១)។ តាមការប៉ាន់ស្មាន វិនិយោគផ្ទាល់ពីបរទេស (FDI) នឹងឡើងដល់ ១,២២ពាន់លានដុល្លារ នៅឆ្នាំ២០១៣ ដែលលើសពីកម្រិតនៅមុនពេលមានវិបត្តិហិរញ្ញវត្ថុសកល ប៉ុន្តែនៅទាបជាងកម្រិតខ្ពស់បំផុតដល់ ១,៤១ពាន់លានដុល្លារ នៅឆ្នាំ២០១២។

កំណើនសេដ្ឋកិច្ចមានកម្រិតខ្ពស់ក៏ពិតមែន ប៉ុន្តែអតិផរណានៅកម្ពុជាមានជាមធ្យមតែ ៥,៥% ពីឆ្នាំ១៩៩៤-២០១១ ហើយរំពឹងថានឹងធ្លាក់ចុះមកត្រឹម ៣-៤% នៅឆ្នាំ២០១៤ ទោះបីអតិផរណាក្នុងតំបន់មានកម្រិតខ្ពស់ ហើយថ្លៃប្រេងឥន្ធនៈ និងស្បៀងអាហារបានស្ទុះឡើងក្ដី។ សូចនាករម៉ាក្រូសេដ្ឋកិច្ចផ្សេងទៀត ក៏បង្ហាញពីស្ថិរភាពក្នុងពេលខាងមុខដែរ៖ នៅឆ្នាំ២០១៣ ប្រាក់រៀលមានស្ថិរភាពទល់នឹងប្រាក់ដុល្លារ, ប្រាក់បញ្ញើនៅធនាគារ និងប្រាក់កម្ចីពីធនាគារ កើនឡើង, សាច់ប្រាក់ងាយស្រួលមានចំនួនគ្រប់គ្រាន់នៅក្នុងទីផ្សារ, ហើយបំណុលខាងក្រៅបានធ្លាក់ចុះបន្តិចពី ២៦% នៃ ផសស នៅឆ្នាំ២០១២ មកត្រឹម ២៣% នៅឆ្នាំ២០១៣។ តាមការប៉ាន់ស្មាន ឱនភាពថវិកាមានប្រហែល ៦,៨% នៃ ផសស ហើយនឹងធ្លាក់ចុះមកទាបជាង ៥,៣% នៅឆ្នាំ២០១៤។ ក្នុងរយៈពេលមធ្យម រដ្ឋាភិបាលមានគោលដៅបញ្ចុះតួលេខនេះថែមទៀត ឲ្យនៅត្រឹម ៣% ដូចមុនពេលមានវិបត្តិហិរញ្ញវត្ថុសកល។ ការប្រមូលចំណូលសាធារណៈ

រូបភាព ១៖ ការនាំចេញអង្ករ គិតជា តោន




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក៏បានប្រសើរឡើងគួរឲ្យពេញចិត្តដែរ ហើយនៅឆ្នាំ២០១៤ រដ្ឋាភិបាល រំពឹងថា ចំណូលពីការបង់ពន្ធ នឹងកើនឡើង ១៤,៥% ធៀបនឹងឆ្នាំមុន។

សូចនាករភាពក្រីក្រស្តង់ដារ ក៏បង្ហាញពីភាពរីកចម្រើនខ្លាំងក្នុងការកាត់បន្ថយភាពក្រីក្រដែរ៖ ពីឆ្នាំ២០០៤ ដល់ ២០១៣ អត្រាភាពក្រីក្របានថយចុះពី ៥៣% មកត្រឹម ២០% នៃចំនួនប្រជាជនសរុប។ ប្រសិនបើនិន្នាការបច្ចុប្បន្នបន្តទៅមុខទៀត គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ស្តីពីការកាត់បន្ថយភាពក្រីក្រឲ្យបានពាក់កណ្តាល ពីឆ្នាំ២០០០ ដល់ ២០១៥ ពិតជាសម្រេចបាន។ ទោះជាយ៉ាងណាក្តី នៅឆ្នាំ២០០៩ CDRI បានរកឃើញថា ប្រជាជនកម្ពុជាប្រហែល ២០% រកចំណូលបានត្រឹមតែចិញ្ចឹមពោះ ដោយមានចំណាយប្រចាំថ្ងៃតិចជាង ១,២៥ដុល្លារ ហើយសូម្បីបច្ចុប្បន្ននេះ ក៏ប្រជាជនកម្ពុជាជាច្រើន មានកម្រិតជីវភាពខ្ពស់ជាងបន្ទាត់ភាពក្រីក្រតែបន្តិចប៉ុណ្ណោះ។ ហេតុនេះ វិបត្តិផ្នែកហិរញ្ញវត្ថុបណ្តាលពីគ្រោះធម្មជាតិ ដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួត ឬក៏ការឈឺថ្កាត់ អាចរុញច្រានពួកគេយ៉ាងលឿនឲ្យធ្លាក់ចូលក្នុងភាពក្រីក្រវិញ។

វិសមភាពលើទ្រព្យធន ជាពិសេស វិសមភាពដីធ្លី និងបញ្ហាទាក់ទងនឹងអសន្តិសុខក្នុងការកាន់កាប់ដី ជាមូលហេតុចម្បងមួយទៀតនៃភាពក្រីក្រ។ នាបច្ចុប្បន្ន ៥៥% នៃគ្រួសារនៅជនបទជាអ្នកក្រីក្រដីធ្លី។ ពួកគេមិនមានដីធ្លី ឬមួយមានដីតិចដាំដុះបានត្រឹមតែចិញ្ចឹមពោះ។ គ្រួសារទាំងនេះ ត្រូវជាប់ផុងក្នុងភាពក្រីក្រ ហើយមិនអាចមានអតិរេកផលិតផល ជួយរួមចំណែកដល់កំណើនសេដ្ឋកិច្ចបានទេ។ សម្តេចនាយករដ្ឋមន្ត្រី បានប្តេជ្ញាកសាងសមត្ថភាពស្ថាប័នរដ្ឋបាលដីធ្លី ដើម្បីការពារតាមច្បាប់នូវសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិរបស់ម្ចាស់ដីតូចៗ ទប់ទល់នឹងការដកហូតដីធ្លី និងដើម្បីជំរុញវិនិយោគ ដោយបានគូសបញ្ជាក់ថានេះជាអាទិភាពគោលនយោបាយនៃ រដ្ឋាភិបាលក្នុងអាណត្តិទី៥។ រដ្ឋាភិបាលនឹងបន្តកិច្ចប្រឹងប្រែងបង្កើនបទបញ្ញត្តិ សម្រាប់គ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ហើយធ្វើការបែងចែកដីធ្លីឡើងវិញនៅតាមតំបន់សមស្រប តាមរយៈសម្បទានដីសង្គមកិច្ច។

រដ្ឋាភិបាល ក៏ត្រូវព្យាយាមដាក់បញ្ចូលប្រជាជនក្រីក្រដែលគ្មានដីកសិកម្ម ទៅក្នុងដំណើរការរីកលូតលាស់ផងដែរ។ នៅតំបន់ជនបទ ការដាក់បញ្ចូលនេះ សំដៅដល់ការបង្កើនឱកាសការងារនៅតាមចំការកៅស៊ូ និងចំការដំឡូងឈើ, ការអភិវឌ្ឍតំបន់នេសាទ, និងការផ្តល់វគ្គបណ្តុះបណ្តាលលើ ការងារក្រៅពីកសិកម្ម។ កំណើនសកម្មភាពនគរូបនីយកម្មយ៉ាងលឿន ដោយសារមានកំណើនក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម កំពុងតែបង្កើតឡើងនូវវណ្ណៈពលករតំបន់ទីក្រុង ដូច្នេះត្រូវមានគោលនយោបាយ សម្រាប់ជួយដោះស្រាយភាពងាយរងគ្រោះ។ រដ្ឋាភិបាល ត្រូវបង្កើតគោលនយោបាយបៀវត្សរ៍ថ្នាក់ជាតិប្រកបដោយយុត្តិធម៌ ដែលថ្លឹងថ្លែងបានល្អរវាង តម្រូវការឲ្យបន្ទុកចំណាយផលិតកម្មមានលក្ខណៈប្រកួតប្រជែង ហើយនឹងតម្រូវការឲ្យពលករមានកម្រិតជីវភាពសមរម្យ។ ត្រូវពង្រឹងផងដែរនូវប្រព័ន្ធសុវត្ថិភាពសង្គម ដើម្បីការពារគ្រួសារងាយរងគ្រោះអំពីវិបត្តិសេដ្ឋកិច្ចផ្សេងៗ។

## ការអភិវឌ្ឍធនធានមនុស្ស

គោលនយោបាយលើការអប់រំ និងបណ្តុះបណ្តាល នឹងដើរតួនាទីគន្លឹះក្នុងពិពិធកម្ម និងការបង្កើនភាពប្រកួតប្រជែងនៃសេដ្ឋកិច្ច។ ការលើកកម្ពស់លទ្ធភាពទទួលបានសេវាបណ្តុះបណ្តាល និងការអប់រំមានគុណភាពល្អ ក៏ជាគោលការណ៍ស្នូលមួយដែរនៃការអភិវឌ្ឍសម្រាប់គ្រប់គ្នា។

ការបង្កើតប្រព័ន្ធអប់រំតាមស្តង់ដារពិភពលោក ដែលអាចជួយជំរុញឲ្យកម្ពុជា ឆ្លងកាត់បាននូវដំណាក់កាលខាងមុខនៃការអភិវឌ្ឍ គឺជាកិច្ចការមួយធំធេង ដោយត្រូវមានការកែលំអទាំងនៅកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា។ មានផ្នែកសំខាន់ៗបី ដែលត្រូវមានគោលនយោបាយដោះស្រាយ គឺ ១) ការបង្កើនគុណភាពការអប់រំនៅគ្រប់កម្រិត, ២) ការពង្រីកលទ្ធភាពទទួលបានការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សាក្នុងទូទាំងប្រទេស និង ៣) ការភ្ជិតគម្លាតរវាងជំនាញដែលត្រូវជំរុញសេដ្ឋកិច្ចឡើង នឹងជំនាញដែលប្រព័ន្ធអប់រំកំពុងផ្តល់ឲ្យ។

កន្លងមក លទ្ធភាពទទួលបានការអប់រំកម្រិតបឋមសិក្សា បានកើនឡើងជាខ្លាំង ប៉ុន្តែលទ្ធភាពទទួលបានការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា នៅតែមានបញ្ហាដែលរដ្ឋាភិបាលត្រូវដោះស្រាយ។ នៅកម្រិតអនុវិទ្យាល័យ ការចុះឈ្មោះចូលរៀនបានធ្លាក់ចុះពី ៥៥% នៅឆ្នាំ២០១១-១២ ដល់ ៥៣% នៅឆ្នាំ២០១២-១៣ និងនៅកម្រិតវិទ្យាល័យ បានធ្លាក់ចុះពី ៣០,៦% ដល់ ២៧%។ ជាទូទៅ អត្រាចុះឈ្មោះចូលរៀននៅតំបន់ជនបទ វាតែងទាបជាងនៅតំបន់ទីក្រុង (រូបភាព ២)។

រដ្ឋាភិបាលបានប្តេជ្ញាចិត្ត ដើម្បីបង្កើនអត្រាចុះឈ្មោះចូលរៀន ដោយបានកសាងសាលារៀនបន្ថែម ជាពិសេសនៅតាមតំបន់ជនបទ និងដាច់ស្រយាល, បង្កើនការលើកទឹកចិត្តដល់គ្រូឲ្យទៅធ្វើការនៅតំបន់ជាយៗ និងលើកទឹកចិត្តសិស្សឲ្យចូលរៀននៅមធ្យមសិក្សា។

នាបច្ចុប្បន្ន គេឃើញមានគម្លាតយ៉ាងធំរវាងទីក្រុង នឹងជនបទ ក្នុងការទទួលបានការអប់រំកម្រិតឧត្តម។ មានគ្រឹះស្ថានឧត្តមសិក្សា ឬវិទ្យាស្ថានអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស (TVET) តិចតួចណាស់ដែលស្ថិតនៅក្រៅទីក្រុង ហើយគ្រួសារជាច្រើននៅតាមជនបទ មិនមានពេលវេលា និងធនធានសម្រាប់ចំណាយដើម្បីទទួលបានសេវាអប់រំ និងបណ្តុះបណ្តាល និង/ឬ មិនបានដឹងពីអត្ថប្រយោជន៍នៃសេវាទាំងនោះទេ។ បញ្ហានេះ បានចូលរួមបង្កើនភាពមានការងារធ្វើមិនពេញលេញនៅតាមជនបទ ហើយទីផ្សារការងារនៅកម្ពុជា ក៏គ្មានប្រសិទ្ធភាព ពីព្រោះពលករដែលនៅសល់ពីកសិកម្ម មិនអាចទទួលបានជំនាញដ៏ចាំបាច់ ដើម្បីចូលរួមចំណែកក្នុងវិស័យផ្សេងទៀតនៃសេដ្ឋកិច្ចទេ។

គុណភាពនៃការផ្តល់សេវាអប់រំ នៅតែមានបញ្ហាចោទនៅក្នុងការអប់រំកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា។ ការផ្តោតខ្លាំងទៅលើស្ថិតិចុះឈ្មោះចូលរៀន ជារឿយៗបានបំបាំងបាត់នូវ បញ្ហាចោទនៅក្នុងរចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំនៅកម្ពុជា។ បញ្ហាស្នូលមួយគឺ ទាំងបឋមសិក្សា និងមធ្យមសិក្សា

មានអត្រាបញ្ចប់ការសិក្សាកម្រិតទាប ជាពិសេសនៅតាមតំបន់ជនបទ (រូបភាព ២)។

ការបង្រៀន និងសម្ភារៈ/កន្លែងបង្រៀន មានគុណភាពទាប ជាលក្ខណៈមួយនៃប្រព័ន្ធអប់រំនៅកម្ពុជា នៅតាមគ្រឹះស្ថានអប់រំសាធារណៈ កម្រិតបឋមសិក្សា និងមធ្យមសិក្សា ជាពិសេសនៅតាមជនបទ ដែលតែងខ្សត់ធនធានជាងគេ។ មានគម្លាតយ៉ាងធំរវាងជនបទ និងទីក្រុង ទាក់ទងនឹងសម្ភារៈបង្រៀន៖ សិស្សនៅជនបទ មានលទ្ធភាពតិចតួចក្នុងការប្រើឧបករណ៍បច្ចេកវិទ្យាព័ត៌មាន ដែលដាក់កំហិតលើការបណ្តុះបណ្តាលជំនាញដ៏ចាំបាច់សម្រាប់ការងារនៅក្នុងសេដ្ឋកិច្ចបែបទំនើប។ គ្រូបង្រៀននៅសាលាតាមជនបទ រកចំណូលបានប្រហែល ១០០ដុល្លារ/ខែ ហើយជារឿយៗត្រូវធ្វើការងារបន្ថែម ឬបង្គ្រប់ចំណូលតាមរយៈសកម្មភាពពុករលួយ ដូចជា ការលក់វិញ្ញាសាប្រឡងដល់សិស្សជាដើម។ ទម្លាប់ទិញវិញ្ញាសាប្រឡងកំពុងរីករាលដាល ហើយវាបង្កជាបញ្ហាផ្នែកគុណភាពក្នុងការផ្តល់ការអប់រំ ព្រោះការខិតខំរៀនសូត្រ និងលទ្ធផលវិសេសក្នុងការសិក្សា គឺអាចជំនួសបានដោយការសូកប៉ាន់។ ម្យ៉ាងទៀត វាក៏ធ្វើឲ្យសិស្សក្រីក្រ ដែលគ្មានលទ្ធភាពបង់ថ្លៃក្រៅផ្លូវការ ត្រូវចាញ់ប្រៀបគេ ពីព្រោះគ្មានធនធានហិរញ្ញវត្ថុដ៏ចាំបាច់ ដើម្បីទទួលបានពិន្ទុល្អ។

គន្លឹះដើម្បីកែលំអការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សានៅកម្ពុជាគឺ ការបង្កើនថវិកាសាធារណៈ និងការផ្តល់អាទិភាពដល់តំបន់ជនបទ ដែលមានជាអាទិ៍ ការផ្តល់ថវិកាសម្រាប់សម្ភារៈបរិក្ខារ និងអាគារសិក្សា, ការតម្លើងបៀវត្សរ៍គ្រូបង្រៀន, ការផ្តល់ការបណ្តុះបណ្តាលកាន់តែប្រសើរដល់គ្រូបង្រៀនមុខវិជ្ជាស្នូល ដូចជា គណិតវិទ្យា, និងការធានាឲ្យកុមារមានកម្រិតអាហារូបត្ថម្ភគ្រប់គ្រាន់ ដើម្បីអាចផ្តំស្មារតីលើការរៀនសូត្រ។ ត្រូវមានផងដែរនូវការប្រឹងប្រែងលើកកម្ពស់វប្បធម៌អប់រំតាមរយៈការជំរុញមាតាបិតាសិស្ស ឲ្យចូលពាក់ព័ន្ធក្នុងការអប់រំ ឲ្យបញ្ជូនកូនតូចៗទៅសាលារៀន និងតាមរយៈការបង្កើនចំនួនសាលាមត្តេយ្យ ការបណ្តុះបណ្តាលគ្រូមត្តេយ្យ និងការលើកកម្ពស់អត្រាចូលរៀននៅកម្រិតមត្តេយ្យសិក្សា។

គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា ក៏មានការបង្រៀន និងសម្ភារៈ/កន្លែងបង្រៀនគុណភាពទាបដែរ។ បញ្ហាធំមួយ គឺការអប់រំកម្រិតឧត្តមសព្វថ្ងៃ មានវិស័យឯកជនជាអ្នកជំរុញឡើង មានបទបញ្ញត្តិគ្រប់គ្រងអន់ខ្សោយ ហើយជារឿយៗផ្តល់អាទិភាពលើប្រាក់ចំណេញ ជាជាងលើគុណភាព។ ដោយគ្មានការត្រួតពិនិត្យគុណភាព ការពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាព និងសមត្ថភាពជំនាញមានស្តង់ដារច្បាស់លាស់ គ្រឹះស្ថានឧត្តមសិក្សាជាច្រើនផ្តល់ការបណ្តុះបណ្តាលមានគុណភាពអន់ និងសមត្ថភាពជំនាញគ្មានតម្លៃ។ សមត្ថភាពបង្រៀនទាប និងបទបញ្ញត្តិអន់ខ្សោយនៃគ្រឹះស្ថានឧត្តមសិក្សា បានប៉ះពាល់អវិជ្ជមានដល់ TVET ដោយសារគេបានជ្រើសរើសបុគ្គលិកមានការបណ្តុះបណ្តាលមិនល្អនៅឧត្តមសិក្សា ឲ្យមកបង្រៀនវគ្គ TVET ហើយបង្កនូវបញ្ហាផ្នែកគុណភាព និងឧបសគ្គដល់ដំណើរការបណ្តុះបណ្តាលមុខវិជ្ជាបច្ចេកទេស ដែលជាកត្តាដ៏ចាំបាច់សម្រាប់ជំរុញសេដ្ឋកិច្ចកម្ពុជានាអនាគត។

ការទាក់ទាញវិស័យឯកជន ឲ្យចូលរួមផ្តល់មូលនិធិដល់គ្រឹះស្ថានបណ្តុះបណ្តាលជំនាញផ្នែកវិទ្យាសាស្ត្រខ្ពស់ៗ និងតាមស្តង់ដារពិភពលោក ក៏សំខាន់ដែរ ព្រោះវាហុចអត្ថប្រយោជន៍ដល់ក្រុមហ៊ុនដែលត្រូវការពលករមានជំនាញខ្ពស់។ សម្ភារៈ/កន្លែងស្របតាមស្តង់ដារពិភពលោក ក៏ជួយទាក់ទាញអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ ឲ្យចូលមកគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជាដែរ។ វិធីនេះសំខាន់បំផុត សម្រាប់ការបង្កើតវប្បធម៌ស្រាវជ្រាវដ៏ប្រសើរ ដែលនឹងជួយដល់ការបង្រៀនមានគុណភាពខ្ពស់។

រូបភាព ២: គម្លាតរវាងតំបន់ជនបទ នឹងទីក្រុង ក្នុងការអប់រំកម្រិតមធ្យមសិក្សា




សម្គាល់៖ អត្រាចុះឈ្មោះដុល សំដៅដល់ ភាគរយនៃប្រជាជនគ្រប់អាយុចូលរៀន ដែលកំពុងរៀននៅសាលា

ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា

ដើម្បីឲ្យការអប់រំ និងបណ្តុះបណ្តាល ជួយលើកកម្ពស់ពិពិធកម្ម និងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ច កម្មវិធីសិក្សាចាំបាច់ត្រូវផ្តល់ដល់កម្លាំងពលកម្មនូវជំនាញដែលនិយោជកត្រូវការ។ សព្វថ្ងៃនេះ ទីផ្សារពលកម្មកម្ពុជាខ្វះខាតនូវ និយោជិតដែលមានជំនាញដ៏ចាំបាច់ៗ ស្របតាមលក្ខខណ្ឌសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងទៅអនាគត។

បញ្ហាចម្បងមួយគឺ ចំនួនច្រើនលើសតម្រូវការនៃពលករដែលបញ្ចប់ការសិក្សាតែមានជំនាញមិនសមស្រប និងកង្វះខាតពលករពាក់កណ្តាលជំនាញ។ វិទ្យាស្ថាន CDRI បានព្យាករណ៍ថា នៅឆ្នាំ២០១២ ទីផ្សារការងារនឹងត្រូវការនិស្សិតបញ្ចប់ការសិក្សាប្រមាណ ១៦.០០០នាក់ ប៉ុន្តែគ្រឹះស្ថានឧត្តមសិក្សាបណ្តុះបណ្តាលបានដល់ទៅ ២៩.០០០នាក់ ហើយគេប៉ាន់ស្មានថា តួលេខនេះនឹងឡើងដល់ ២២.០០០នាក់ ទល់នឹង ៧០.០០០នាក់ នៅឆ្នាំ២០១៤ ។

អ្នកបង្កើតគោលនយោបាយត្រូវធានាថា ប្រព័ន្ធអប់រំនៅកម្ពុជាជួយភ្ជិតគម្លាតរវាង ការរំពឹងទុករបស់យុវជនយុវនារីកម្ពុជាដែលចូលទៅក្នុងទីផ្សារការងារ និងការងារជាក់ស្តែងដែលមានសម្រាប់ពួកគេ។ ដូច្នេះ ត្រូវតែគិតគូរឡើងវិញ លែងលើកទឹកចិត្តនិស្សិតឲ្យសិក្សានូវ មុខវិជ្ជាសម្រាប់ការងារតាមការិយាល័យដែលមានតម្រូវការតិចជាង និងត្រូវកាត់បន្ថយក្នុងផ្នែកផ្គត់ផ្គង់នូវឧបសគ្គរារាំងដល់ការអភិវឌ្ឍជំនាញនានា សម្រាប់ជួយជំរុញវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច ព្រមទាំងវិស័យកាត់ដេរ និងកម្មន្តសាលផងដែរ។

បញ្ហាសំខាន់មួយគឺ ការលើកទឹកចិត្តនិស្សិតឲ្យចូលរៀនក្នុង TEVT ជាជាងរៀនយកសញ្ញាប័ត្រ ដើម្បីក្លាយជាបុគ្គលិកតាមការិយាល័យ។ សព្វថ្ងៃក្នុងគំនិតមហាជន TEVT មានរូបភាពអវិជ្ជមានមួយថា ជាប់ទាក់ទងនឹងការងារប្រើកម្លាំងកាយ។ រូបភាពបែបនេះនៃ TVET ត្រូវតែផ្លាស់ប្តូរឲ្យបាន ដើម្បីឲ្យនិស្សិតពូកែៗដកចិត្តចេញពីកម្មវិធីសិក្សាសម្រាប់ការងារតាមការិយាល័យ។

កម្មវិធីសិក្សានៃគម្រោង TVET ត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់និយោជកប្រសិនបើគេចង់ឲ្យពលករមានជំនាញសមស្រប។ ការត្អូញត្អែរដូចៗគ្នាមួយរបស់និយោជក ក្នុងវិស័យកម្មន្តសាល និងសេវាកម្ម គឺកង្វះការសង្កត់ធ្ងន់លើការអភិវឌ្ឍជំនាញទន់ដែលបានរារាំងដល់ការរីកចម្រើន ក្នុងឥរិយាបថនៅកន្លែងធ្វើការ, ការដោះស្រាយបញ្ហា, និង គំនិតច្នៃប្រឌិត។ ការកសាងយន្តការប្រកបដោយប្រសិទ្ធភាព ដែលធានាឲ្យតម្រូវការនៃវិស័យឯកជនមានឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីសិក្សារបស់ TVET គឺសំខាន់ណាស់សម្រាប់ឲ្យកម្ពុជាធ្វើពិពិធកម្ម ចូលទៅក្នុងឧស្សាហកម្មថ្មីៗ និងឈានឡើងក្នុងខ្សែចង្វាក់បង្កើតតម្លៃ។

## ការពង្រឹងបរិយាកាសអាជីវកម្ម

សមាជិកភាពក្នុង AEC មានន័យថា ផលិតករនៅកម្ពុជាមានទីផ្សារជាសក្តានុពលដល់ទៅ ៦០០លានអ្នកប្រើប្រាស់ ហើយអ្នកបង្កើតគោលនយោបាយ មានភារកិច្ចត្រូវជួយធានាថា សក្តានុពលនេះប្រែក្លាយទៅជាកំណើនពិតៗ ដោយបង្កើតនូវបរិយាកាសមួយ ដែលលើកទឹកចិត្តឲ្យមានការនាំចេញចម្រុះសម្រាប់បំពេញតាមតម្រូវការទីផ្សារ។ ការជំរុញឧស្សាហកម្មថ្មីៗមានតម្លៃបន្ថែមខ្ពស់ នឹងកាន់តែសំខាន់ខ្លាំងឡើង នៅពេលដែលកម្ពុជាឡើងឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងមានឧត្តមភាពប្រៀបធៀបផ្លាស់ប្តូរ លែងពឹងផ្អែកលើពលកម្មមានតម្លៃទាប។

អ្នកជំរុញពិពិធកម្ម ក្នុងសេដ្ឋកិច្ចនៃប្រទេសជាច្រើន គឺសហគ្រាសខ្នាតតូចនិងមធ្យម (SME) ដូចគេតែងលើកឡើងក្នុងករណីនៃការផ្លាស់ប្តូរសេដ្ឋកិច្ចនៅប្រទេសចិន។ សមាជិកភាពក្នុង AEC អាចនាំឲ្យការអភិវឌ្ឍវិស័យ SME នៅកម្ពុជា ត្រូវជាប់គាំង ដោយសារមានលំហូរចូលច្រើនៗនូវ ផលិតផលនាំចូលថោកៗ។ រដ្ឋាភិបាលត្រូវជួយបង្កើនផលិតភាព SMEs ដែលសព្វថ្ងៃមិនសូវមានការត្រួតពិនិត្យទេ តាមការបង្កើតបទបញ្ញត្តិគ្រប់គ្រងរបៀបរបបធ្វើអាជីវកម្ម ដូចជា ការកំណត់ស្តង់ដារធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតារាងតុល្យការ ដើម្បីអាចធ្វើសវនកម្មបានត្រឹមត្រូវ។ ការធ្វើបែបនេះ នឹងជួយបង្កើនការផ្តល់កម្ចីពីសំណាក់ធនាគារ, លើកទឹកចិត្តដល់វិនិយោគ, និងផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការតភ្ជាប់ជាមួយក្រុមហ៊ុនធំៗ នៅក្នុងខ្សែចង្វាក់ផលិតកម្មក្នុងតំបន់។ ការធ្វើឲ្យរបៀបរបបហិរញ្ញវត្ថុមានលក្ខណៈផ្លូវការឡើង ក៏នឹងជួយឲ្យរដ្ឋាភិបាលប្រមូលពន្ធបានកាន់តែងាយស្រួល អំពី SMEs ព្រមទាំងបង្កើនលទ្ធភាពផ្នែកសារពើពន្ធ ដើម្បីផ្តល់ទុនជួយលើកកម្ពស់ការផ្តល់សេវាសង្គម ដែលកំពុងមានតម្រូវការខ្លាំង និងផ្តល់ធនធាន សម្រាប់ការពង្រឹងសេដ្ឋកិច្ច ត្រៀមទប់ទល់នឹងការប៉ះទង្គិចផ្សេងៗពីផ្នែកខាងក្រៅ។

នាបច្ចុប្បន្ន ច្បាប់វិនិយោគមានគោលដៅទាក់ទាញ FDI ដូច្នេះ ត្រូវតែកែសម្រួលឡើងវិញដើម្បីផ្តល់ការលើកទឹកចិត្តដល់ SMEs ឲ្យចូលរួមក្នុងសេដ្ឋកិច្ចផ្លូវការ។ ក្នុងពេលជាមួយគ្នា គោលនយោបាយសារពើពន្ធ ក៏គួរជួយសម្របសម្រួលឲ្យ SMEs ទទួលបានអត្ថប្រយោជន៍ពី FDI តាមការលើកទឹកចិត្តឲ្យបង្កើតឧស្សាហកម្មបន្ទាប់បន្សំ សម្រាប់បម្រើឧស្សាហកម្មកម្មន្តសាល ដូចជា ផលិតកម្មរថយន្តជាដើម។ ជាការសំខាន់ណាស់ដែលបទបញ្ញត្តិនានា មានបំពេញបន្ថែមដោយសេវាគាំទ្រផ្សេងៗ ដើម្បីជំរុញយុទ្ធសាស្ត្រសម្រាប់ឲ្យ SMEs ជ្រៀតចូលទៅក្នុងបណ្តាញផលិតកម្ម រីកធំចូលទៅក្នុងទីផ្សារថ្មីៗ និងបង្កើនដើមទុនផ្នែកបច្ចេកទេស និងការគ្រប់គ្រង។

ការពង្រីកសកម្មភាពសហគ្រិនភាព និងការបង្កើតបទបញ្ញត្តិគ្រប់គ្រងរបៀបរបបធ្វើអាជីវកម្ម នឹងនាំឲ្យមានកំណើនតម្រូវការឥណទានពីវិស័យផ្លូវការ។ សញ្ញាសំខាន់ៗនៃការប្រែប្រួលបរិយាកាសម៉ាក្រូហិរញ្ញវត្ថុ បានបង្ហាញឡើងរួចជាស្រេច។ ជាអាទិ៍ តាមតួលេខរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) អនុបាតឥណទាន ធៀបនឹង ផសស បានកើនឡើងយ៉ាងលឿន ពីរវាង ៦% ទៅ ៩% ក្នុងអំឡុងឆ្នាំ២០០០-២០០៥ ដល់ជិត ៤០% ក្នុងឆ្នាំ២០១៣។ កំណើនឥណទានយ៉ាងលឿននេះ កើតមានឡើងនៅក្នុងទីផ្សារមួយមានមនុស្សកកកុញ គ្មានបទបញ្ញត្តិច្បាប់គ្រប់គ្រាន់ និងមានការប្រើប្រាក់ដុល្លារជាសំខាន់ ដែលអាចបង្កនូវហានិភ័យនៃវិបត្តិហិរញ្ញវត្ថុនៅកម្រិតម៉ាក្រូ។

យន្តការដ៏សំខាន់ សម្រាប់គ្រប់គ្រងត្រួតពិនិត្យលើអ្នកផ្តល់ឥណទាន គួរតែបង្កើតឡើង។ អ្នកធ្វើគោលនយោបាយត្រូវថ្លឹងថ្លែងឲ្យបានល្អ រវាងតម្រូវការកាត់បន្ថយហានិភ័យផ្នែកម៉ាក្រូហិរញ្ញវត្ថុ និងការផ្តល់ក្របខ័ណ្ឌដ៏អំណោយផលមួយសម្រាប់កំណើនឥណទាន និងការពង្រីកសេវាឥណទានក្នុងសេដ្ឋកិច្ចទាំងមូល ជាពិសេសសម្រាប់ SMEs ។

កំណើន FDI នៅផ្ទៃក្នុងអាស៊ាន ដែលរំពឹងថានឹងទទួលបានតាមការបង្កើត AEC, ដំណើរការពិនិត្យតាមដានជាផ្លូវការ, និងកំណើនផលិតភាព, នឹងផ្តល់ទំនុកចិត្តដល់វិនិយោគិនបរទេស ព្រមទាំងជួយរួមចំណែកបង្កើន FDI សម្រាប់ SME។ ប៉ុន្តែកំណើន FDI ក៏ជាប្រភពនៃហានិភ័យថ្មីៗដែរ។ ដូចបានពិនិត្យឃើញក្នុងវិបត្តិសេដ្ឋកិច្ចឆ្នាំ២០០៩ នៅពេលលក្ខខណ្ឌខាងក្រៅមានការផ្លាស់ប្តូរ វិនិយោគិនបរទេសក៏ឆាប់ផ្អើលរត់ចេញទៅវិញដែរ។ ដូច្នេះជាការសំខាន់ ដែលរដ្ឋាភិបាលត្រូវបង្កើនការត្រួតពិនិត្យ ដើម្បីអាចដឹងច្បាស់ពីបំណុល FDI និងគ្រប់គ្រងបានលើការប៉ះទង្គិចផ្សេងៗ។

ការបង្កើតបទបញ្ញត្តិគ្រប់គ្រងរបៀបរបបវិនិយោគ គួរមានបំពេញបន្ថែម ដោយការរៀបចំឲ្យច្រកធ្វើពាណិជ្ជកម្មសំខាន់ៗក្លាយជាផ្លូវការឡើង។ ចំណុចនេះជាបញ្ហាបន្ទាន់មួយ នៅចំពោះមុខការបង្កើត AEC នៅឆ្នាំ២០១៥។ ផលិតករនឹងទទួលបានអត្ថប្រយោជន៍ពី AEC លុះត្រាតែរដ្ឋាភិបាលមានជោគជ័យក្នុងការពង្រីក និងជំរុញវប្បធម៌មួយដែលទទួលយកការប្រើប្រាស់យន្តការពាណិជ្ជកម្មផ្លូវការ នៅក្នុងសេដ្ឋកិច្ចទាំងមូល។

រង្វាស់ដ៏សំខាន់មួយនៃឧបសគ្គដែលរារាំងការអនុវត្ត AEC គឺកំហិតផ្សេងៗលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ានបូក៥ ពីព្រោះកិច្ចព្រមព្រៀងទាំងពីរនេះ លើកកម្ពស់ពាណិជ្ជកម្មតាមរយៈក្របខ័ណ្ឌកាត់បន្ថយពន្ធគយដូចគ្នា។ នាបច្ចុប្បន្ន មានតែ ៤៧% នៃពាណិជ្ជកម្មរបស់កម្ពុជាប៉ុណ្ណោះ ដែលហូរតាមក្របខ័ណ្ឌអាស៊ានបូក៥ ទោះបីវាមានរបបពន្ធគយទាបជាងក្តី។ អត្រាពន្ធគយទាបវាបាត់ផលប្រយោជន៍អស់ ដោយសារតែការចំណាយ និងបញ្ហាស្មុគស្មាញផ្សេងៗ ក្នុងការអនុវត្តតាមលក្ខណៈវិនិច្ឆ័យរបស់អាស៊ានបូក៥។ គេហៅរបាំងដែលរារាំងដល់ការប្រើប្រាស់ក្របខ័ណ្ឌពាណិជ្ជកម្មសេរីទាំងនេះថា វិធានការមិនមែនពន្ធគយ (Non Tariff Measures: NTMs)។

NTM ធំបំផុតដែលរារាំងផលិតករកម្ពុជា ក្នុងការប្រើប្រាស់ក្របខ័ណ្ឌអាស៊ានបូក៥ គឺការតម្រូវឲ្យមានអាជ្ញាប័ណ្ណនាំចេញ។ NTMs មិនមែនជាបញ្ហាចោទសម្រាប់តែប្រទេសកម្ពុជាមួយនោះទេ។ ជាក់ស្តែង វាបានប៉ះពាល់ដល់ផលិតផលច្រើនបែបយ៉ាងក្នុងទូទាំងអាស៊ាន។ ដើម្បីឲ្យកម្ពុជា និងប្រទេសឯទៀតក្នុងតំបន់ទទួលបានអត្ថប្រយោជន៍ពី AEC ដែលជាទីផ្សារតែមួយនេះ គេត្រូវលុបបំបាត់ NTMs និងតម្រឹមលក្ខណៈវិនិច្ឆ័យសម្រាប់ចូលទៅក្នុង AEC ដើម្បីកុំឲ្យអ្នកនាំចេញបាក់ទឹកចិត្តក្នុងការប្រើប្រាស់ក្របខ័ណ្ឌនេះជាយានសម្រាប់ធ្វើពាណិជ្ជកម្ម។ លើសពីនេះទៀត រដ្ឋាភិបាល ត្រូវផ្តល់ជំនួយបន្ថែមទៀតទៅឲ្យវិស័យឯកជន (ជាពិសេស SMEs) ដើម្បីឲ្យពួកគេយល់ថា តើ AEC មានពាក់ព័ន្ធអ្វីខ្លះដល់ពួកគេ - តើវាអាចផ្តល់អត្ថប្រយោជន៍អ្វី និងមានហានិភ័យអ្វីខ្លះ។ នាបច្ចុប្បន្ន អាជីវកម្មជាច្រើននៅមិនទាន់ដឹងច្បាស់ទេពីភាពពាក់ព័ន្ធនៃ AEC និងទទួលបានព័ត៌មានតិចតួចណាស់ពីរដ្ឋាភិបាល។ AEC អាចផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់កម្ពុជា ប្រសិនបើប្រជាជនកម្ពុជាមានការយល់ដឹង និងអាចប្រើប្រាស់ប្រព័ន្ធនេះប្រកបដោយប្រសិទ្ធភាព។

## ការលើកកម្ពស់ការតភ្ជាប់ទំនាក់ទំនង

ការបង្កើនសមត្ថភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរឹង និងទន់ សំខាន់ខ្លាំងណាស់ ដើម្បីជំរុញឲ្យរដ្ឋាភិបាលអាចសម្រេចតាមគោលដៅនាំចេញប្រកបដោយមហិច្ឆតារបស់ខ្លួន, ធ្វើពិពិធកម្មទៅរកផលិតផលថ្មីៗ និងឈានឡើងនៅក្នុងខ្សែចង្វាក់បង្កើតតម្លៃ។

ករណីអង្ករ ជាឧទាហរណ៍យ៉ាងច្បាស់មួយនៃឧបសគ្គដែលរារាំងគោលបំណងដ៏ធំធេងក្នុងការនាំចេញ។ រដ្ឋាភិបាលមានគោលដៅនាំចេញអង្ករ ១លានតោន/ឆ្នាំ នៅត្រឹមឆ្នាំ២០១៥ ដើម្បីក្លាយជាប្រទេសនាំចេញអង្ករធំបំផុតទី៣ នៅលើពិភពលោក។ ទោះជារោងម៉ាស៊ីនកិនស្រូវអាចផលិតអង្ករបាន ១លានតោនក្នុងមួយឆ្នាំក្តី ក៏ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន (កំពង់ផែ, សមត្ថភាពដឹកជញ្ជូនផ្លូវគោក) មិនទាន់មានគ្រប់គ្រាន់សម្រាប់ដឹកជញ្ជូនអង្ករយ៉ាងច្រើនដូច្នេះទេ។ ធនាគារពិភពលោកបង្ហាញថា ប្រសិនបើស្ថានភាពនេះនៅតែបន្តនោះ អង្ករកម្ពុជានឹងមានតម្លៃខ្ពស់ជាងប្រទេសឯទៀតក្នុងតំបន់ ដោយសារតែចំណាយដឹកជញ្ជូនដែលខ្ពស់ជាងនៅប្រទេសវៀតណាមដល់ទៅ៤០%។ជាក់ស្តែងណាស់ សមត្ថភាពដឹកជញ្ជូនចាំបាច់ត្រូវកែលំអ ដើម្បីអាចសម្រេចបានតាមគោលដៅនាំចេញអង្ករ។

តំណភ្ជាប់កាន់តែប្រសើរជាមួយប្រទេសជិតខាង នឹងអនុញ្ញាតឱ្យសេដ្ឋកិច្ចកម្ពុជា បានចូលរួមក្នុងបណ្តាញផលិតកម្មទាន់ពេលល្មម (Just In-time Production: JIP) នៅក្នុងតំបន់។ JIP ជាលក្ខណៈមួយនៃសេដ្ឋកិច្ចអាស៊ាន ដែលអនុញ្ញាតឱ្យទំនិញកម្មន្តសាលអាចផលិតបានលឿន និងចំណាយអស់តិចបំផុត។ លក្ខណៈសំខាន់មួយនៃគំរូផលិតកម្មនេះ គឺការតភ្ជាប់កម្រិតខ្ពស់ និងការសម្របសម្រួលល្អក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ ក្នុងនេះល្បឿន និងភាពទៀងទាត់អាចទាយទុកបាន ក្នុងទូទាំងខ្សែចង្វាក់ផ្គត់ផ្គង់ វាសំខាន់បំផុត ដើម្បីឲ្យប្រព័ន្ធនេះដំណើរការបានរលូន។

ការធ្វើសមាហរណកម្មចូលក្នុងបណ្តាញ JIP នឹងបង្កើតតម្រូវការនូវផលិតផល និងដំណើរការឧស្សាហកម្មច្រើនបែបយ៉ាង ព្រមទាំងជំរុញការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្មរបស់កម្ពុជា។ ក្នុងរយៈពេលមធ្យម ជំនាញផ្សេងៗដែលទទួលបានតាមរយៈការធ្វើសមាហរណកម្មចូលទៅក្នុងបណ្តាញ JIP នឹងលើកទឹកចិត្តឧស្សាហកម្មមានតម្លៃបន្ថែមខ្ពស់ ឲ្យចូលមកដំណើការនៅកម្ពុជា ព្រោះលក្ខខណ្ឌទីផ្សារបានផ្លាស់ប្តូរក្នុងទូទាំងតំបន់។

ការសម្របសម្រួល ឲ្យទំនិញអាចហូរចុះឡើងបានប្រកបដោយប្រសិទ្ធភាព មានន័យថា កម្ពុជាអាចបានចំណេញពីកំណើនពាណិជ្ជកម្ម។ ទីតាំងអាស៊ាននៅជិតជាប់នឹងប្រទេសមានសេដ្ឋកិច្ចខ្លាំងៗនៅអាស៊ីបូព៌ា ដូចជា ចិន ជប៉ុន កូរ៉េខាងត្បូង និង តៃវ៉ាន់ ជាដើម ជួយផ្តល់ឲ្យកម្ពុជានូវឱកាសបង្កើតមូលធនបានពីការផ្លាស់ប្តូរពាណិជ្ជកម្មឆ្លងកាត់តំបន់។ ដោយឡែក ក្នុងប្រាំឆ្នាំកន្លង

មកនេះ ពាណិជ្ជកម្មបានកើនឡើង ១២% ជារៀងរាល់ឆ្នាំ។ ទីតាំងជាយុទ្ធសាស្ត្ររបស់កម្ពុជានៅចន្លោះមណ្ឌលប្រសព្វធំៗ ក្នុងតំបន់ គឺក្រុងហូជីមិញ និងក្រុងបាងកក មានន័យថា កម្ពុជាមានទីតាំងល្អ ដើម្បីទទួលបានអត្ថប្រយោជន៍អំពី ពាណិជ្ជកម្មឆ្លងកាត់។ អត្ថប្រយោជន៍ទាំងនេះ រួមមាន កំណើនប្រាក់ចំណូល ការប្រកួតប្រជែង និងប្រសិទ្ធភាពក្នុងការផ្ដល់សេវាដឹកជញ្ជូន និងកំណើនតម្រូវការនូវសេវាគាំទ្រផ្សេងៗ ដូចជា គណនេយ្យ និងច្បាប់ជាដើម។

ដើម្បីឲ្យកម្ពុជាអាចក្លាយជាស្នូលសំខាន់មួយ នៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននោះ អ្នកបង្កើតគោលនយោបាយត្រូវប្រើវិធីសាស្ត្រមួយមានបីមុខព្រួញ ដើម្បីជំនះលើឧបសគ្គនៃសមត្ថភាពមានកម្រិត នៅក្នុងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន។ ទី១ ត្រូវបន្តកិច្ចប្រឹងប្រែងកែលំអហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា បានឈានទៅមុខច្រើនហើយ ជាពិសេស ក្នុងការកែលំអហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរូបវន្ត មានជាអាទិ៍ ផ្លូវថ្នល់ ផ្លូវដែក និងកំពង់ផែ។ ដោយឡែក ច្រករបៀងសេដ្ឋកិច្ចខាងត្បូង (ADBs Southern economic corridor) បានផ្ដល់នូវក្របខ័ណ្ឌគោលនយោបាយ និងមូលនិធិសម្រាប់តភ្ជាប់ប្រទេសកម្ពុជាឲ្យបានកាន់តែប្រសើរជាមួយ វៀតណាម និងថៃ។

ទី២ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ត្រូវតែមានបំពេញបន្ថែមដោយការកសាងសេវាភស្តុភារបែបទំនើប និងស្របតាមស្តង់ដារពិភពលោក។ សន្ទស្សន៍ការងារភស្តុភារ (Logistics Performance Index: LPI) ឆ្នាំ២០១២ របស់ធនាគារពិភពលោក បានចាត់ថ្នាក់កម្ពុជានៅលេខ ១០១ ក្នុងចំណោម ១៥៥ប្រទេស ហើយវៀតណាម នៅលេខ ៥៣ និង ថៃ ៣៨។ សមត្ថភាពទាបផ្នែកភស្តុភារ បានប៉ះពាល់ដល់ផលិតករនៅគ្រប់កម្រិតក្នុងទីផ្សារ ដោយបន្ថែមបន្ទុកចំណាយទៅលើការនាំចេញ និងបង្កើតភាពមិនច្បាស់លាស់ក្នុងការផ្ដល់សេវា។ បញ្ហាដ៏សំខាន់មួយ គឺការដាក់បញ្ចូលគ្នានូវ សេវាភស្តុភារនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់។ នាបច្ចុប្បន្ន សេវាភស្តុភារនៅថ្នាក់មូលដ្ឋានមានលក្ខណៈក្រៅផ្លូវការ មានតម្លៃនិងពេលកំណត់មិនសូវទៀងទាត់-មិនអាចទាយទុកបាន និងមិនមានការតភ្ជាប់ល្អទៅនឹងបណ្ដាញភស្តុភារឆ្លងកាត់ព្រំដែន។ នៅព្រំដែន កុងតឺនែរត្រូវតែលើកចេញ និងដាក់ទៅលើយានយន្តខុសៗគ្នា ដែលត្រូវចំណាយអស់ ១០០ដុល្លារ ថែមទៀតក្នុងមួយកុងតឺនែរ។

ដើម្បីបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធភស្តុភារ រដ្ឋាភិបាលត្រូវចាត់វិធានការដាក់បញ្ចូលគ្នានូវ ប្រព័ន្ធដឹកជញ្ជូននៅតាមមូលដ្ឋាន (ជាពិសេស ប្រព័ន្ធនៅតាមតំបន់ដាច់ស្រយាល) ទៅក្នុងបណ្ដាញដឹកជញ្ជូនថ្នាក់ជាតិ។ ម្យ៉ាងទៀតគួរបង្កើតយន្តការផ្សេងៗ ដើម្បីកែលំអការផ្ដល់ព័ត៌មានអំពី កិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនអន្តរជាតិ សំដៅលើកកម្ពស់សហប្រតិបត្តិការឆ្លងកាត់ព្រំដែន។ រដ្ឋាភិបាលក៏ត្រូវលើកកម្ពស់ការប្រកួតប្រជែងផ្នែករថយន្តដឹកជញ្ជូន កំពង់ផែ និងការដឹកជញ្ជូនតាមអាកាសដែរ ដើម្បីកែលំអស្តង់ដារសេវាកម្ម និងជួយឲ្យផលិតករមានជម្រើសលើការផ្ដល់សេវានេះ។

ទី៣ កង្វះសមត្ថភាពស្ថាប័ន ដើម្បីអនុវត្តនីតិវិធីគយប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព បានបង្កើនបន្ទុកចំណាយលើប្រតិបត្តិការ និងការយឺតយ៉ាវ។ រដ្ឋាភិបាលបានខិតខំតម្រឹមនីតិវិធីគយ ស្របតាមផែនទីបង្ហាញផ្លូវទៅកាន់ AEC នៅឆ្នាំ២០១៥ ប៉ុន្តែកង្វះសមត្ថភាពស្ថាប័ន សម្រាប់អនុវត្តគោលនយោបាយនៅព្រំដែន បាននាំឲ្យមានការយកកម្រៃក្រៅផ្លូវការ ដែលក្លាយជាចំណាយបន្ថែមមួយទៀតលើផលិតផលរបស់កម្ពុជា។ ដូច្នេះជាការសំខាន់បំផុត ដែលរដ្ឋាភិបាលត្រូវជំរុញមន្ត្រីកុំឲ្យយកប្រាក់កម្រៃ "ក្រៅផ្លូវការ"។

## កិច្ចសហប្រតិបត្តិការ និងការកសាងសមត្ថភាពស្ថាប័ន ជាគន្លឹះសម្រាប់ថ្ងៃអនាគត

សមត្ថភាពស្ថាប័ន ជាចំណងដែលតភ្ជាប់ពិពិធកម្មសេដ្ឋកិច្ច កំណើនភាពប្រកួតប្រជែង នឹងការអភិវឌ្ឍសម្រាប់គ្រប់គ្នា។ គន្លឹះដើម្បីសម្រេចបានវិបុលភាព និងកំណើនសេដ្ឋកិច្ចសម្រាប់កម្ពុជាក្នុងប៉ុន្មានឆ្នាំខាងមុខនេះ គឺការកសាងសមត្ថភាពស្ថាប័នសម្រាប់អនុវត្តគោលនយោបាយ និងច្បាប់ ឲ្យមានភាពប្រាកដប្រជា ប្រសិទ្ធភាព តម្លាភាព និងសមភាពនៅគ្រប់កម្រិត។

ការកំណត់ការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព ត្រូវមានសហប្រតិបត្តិការ និងការសម្របសម្រួលរវាងមន្ទីរក្រសួង អ្នកធ្វើគោលនយោបាយ និងអ្នកពាក់ព័ន្ធនានា និងត្រូវមានការចូលរួមពីវិស័យឯកជន ដើម្បីញ៉ាំងឲ្យយន្តការសម្រាប់ជួយសម្រួលពាណិជ្ជកម្ម និងវិនិយោគ វាសមស្របតាមតម្រូវការជាក់ស្តែង។ អ្នកត្រូវចូលរួម មានជាអាទិ៍ អ្នកដឹកនាំក្រុមហ៊ុនធំៗ, តំណាង SMEs និងផលិតករស្រូវអង្ករ, និងស្ថាប័នស្រាវជ្រាវ។ យន្តការនានាត្រូវតែពង្រឹងឡើង ដើម្បីលើកកម្ពស់សហប្រតិបត្តិការអន្តរក្រសួង និងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវធនធានរបស់វិស័យឯកជន តាមការកសាងភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPPs)។

ដើម្បីកសាងប្រព័ន្ធការិយាធិបតេយ្យ ឲ្យមានប្រសិទ្ធភាពខ្ពស់ គេត្រូវតែធ្វើការងារនៅក្នុងក្របខ័ណ្ឌដែលមានស្រាប់ ដូចជា ការកសាងសមត្ថភាពអាជ្ញាធរមូលដ្ឋានតាមរយៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ការកសាងសមត្ថភាពប្រព័ន្ធតុលាការតាមរយៈគម្រោងបណ្ដុះបណ្ដាលសម្រាប់មន្ត្រីរាជការ, និងការរៀបចំឡើងវិញនូវ កាំថ្នាក់ប្រាក់បៀវត្សរ៍របស់រដ្ឋបាលស៊ីវិលទាំងមូល ដើម្បីកាត់បន្ថយតម្រូវការរកកម្រៃក្រៅផ្លូវការពីសំណាក់មន្ត្រីរាជការ។ ក្នុងការកសាងប្រព័ន្ធការិយាធិបតេយ្យនេះ ក៏ត្រូវមានការអភិវឌ្ឍស្ថាប័នថ្មីៗ ឲ្យបានស្របតាមតម្រូវការជាក់ស្តែង ដោយឈរលើគោលការណ៍មានតម្លាភាព និងអភិបាលកិច្ចល្អ ដូចជា គណៈកម្មាធិការសុរិយោដី និងក្រុមប្រឹក្សាអាជ្ញាកណ្ដាលជាដើម ដើម្បីកាត់បន្ថយភាពមិនប្រាកដប្រជាសម្រាប់វិនិយោគិន។ ចាំបាច់ត្រូវពង្រីកលទ្ធភាពប្រើប្រាស់ស្ថាប័នទាំងនេះ ឲ្យបានទៅដល់គ្រប់ផ្នែកតូចៗនៃសង្គមផង ព្រមទាំងធានានូវការគោរព និងអនុវត្តកិច្ចសន្យា និងការដោះស្រាយទំនាស់ផ្សេងៗ ទៅតាមផ្លូវច្បាប់ ដោយមិនផ្អែកទៅលើទំនាក់ទំនង ឬប្រភពអំណាចរបស់អ្នកពាក់ព័ន្ធនោះទេ។